ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សាលក្រមព្រហ្មទណ្ឌ

.លេខ ១១៤ "ខ"
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
.សំណុំរឿងព្រហ្មទណ្ឌលេខ ៦១៨
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩
.សំណុំរឿងស៊ើបសួរលេខ ១៧
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០
.សំណុំរឿងជំនុំជម្រះលេខ ២៤០
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០ នាទីរសៀល នៅសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

.លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

### តំណាងអយ្យការ

.លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

.លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

.ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦១៨ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] វ៉ៃន ភេទប្រុស អាយុ៦៤ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង ( ក្រៅឃុំ ) ។

២.ឈ្មោះ [redacted] សាវ៉ុន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតភូមិ និង ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] វ៉ៃន (រ) ម្តាយឈ្មោះ [redacted] សុខ (រ) នៅលីវ ( ក្រៅឃុំ ) ។

ត្រូវជាប់ចោទពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា និង ហិង្សាទៅកាន់កាប់លើអចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ៦៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ។

.មានលោក អន សម័យ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ។

### ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩ វេលាម៉ោង១០ព្រឹក នៅចំនុចជាយព្រែង ស្ថិតនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មានករណីបទល្មើស ធ្វើឱ្យខូចខាតដោយចេតនា និង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ដែលបង្កឡើងដោយជនជាប់ចោទ

ឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន បានយកគ្រឿងចក្រទៅឈូសឆាយដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង បណ្ដាលឱ្យខូចខាតដំណាំ និងបាត់បង់ដីអស់ចំនួន ៥.៤០០ម៉ែត្រការ៉េ តាមការឆ្លើយបញ្ជាក់របស់ជនរងគ្រោះ ។

.បានឃើញ របាយការណ៍សំយោគលេខ: ៦៣ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។

.បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៤២៥៤ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៤០៦៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៤៣ ចុះថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង បានឆ្លើយថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង១០ព្រឹក ឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន បានយកគ្រឿងចក្រមកឈូសឆាយយកដីចំការរបស់ខ្លួន ដែលមានទំហំក្បាលដី២០ម៉ែត្រ និងបណ្ដោយ១៣០ម៉ែត្រ និង មួយចំហៀងទៀតមានក្បាលដី១១៥ម៉ែត្រ ជំរៅកន្ទុយក្រោយ៥៤ម៉ែត្រ ។

ដីរបស់ខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៨៧ មានពាក្យកាន់កាប់នៅក្នុងឆ្នាំ១៩៩០ មានរដ្ឋអំណាចទទួលស្គាល់ត្រឹមត្រូវ ខ្លួនបានលើកទំនប់ធ្វើជាព្រំ និង ដាំឈូករយៈពេល៥ ទៅ ៦ឆ្នាំ មកហើយ មិនដែលមានជនណាមកតវ៉ាជំទាស់ទេ នៅថ្ងៃកើតហេតុឈ្មោះ [redacted] សាវ៉ុន និង ឈ្មោះ [redacted] វ៉ូន បានយកថ្នាំទៅបាញ់លើឈូករបស់ខ្លួនខូចខាតទំហំក្បាលដី ៥ម៉ែត្រ គុណនឹង ៥០០ម៉ែត្រ និង ឈូសឆាយដីទំនប់ព្រំរបស់ខ្លួនចោល ពេលខ្លួនទៅសួរនាំ ពួកគេបានគំរាមកំហែងមកលើខ្លួន នៅដៃពួកគេមានកាំបិត ទើបខ្លួនប្ដឹងមកតុលាការដើម្បីឱ្យជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

នៅក្នុងរឿងហេតុនេះខ្លួនសូមប្ដឹងទៅលើឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន ទាមទារការខូចខាតដំណាំឈូក និងដីទំនប់ព្រំ និងជម្ងឺចិត្តចំនួន៤០(សែសិបលាន)រៀល និង ប្ដឹងឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទនេះតាមច្បាប់ ។

.សាក្សីឈ្មោះ [redacted] ឡឿន បានឆ្លើយថា កាលពីដើមដីនេះរបស់ឈ្មោះ [redacted] វុទ្ធី លក់ទៅឱ្យឈ្មោះ [redacted] វ៉ូន មានកិច្ចសន្យាកល់ទិញមានរដ្ឋអំណាចដឹងឮ ដីនេះមានព្រំប្រទល់ខាងកើតជាប់ដីរបស់ឈ្មោះ [redacted] ហៀង នៅថ្ងៃកើតហេតុឈ្មោះ [redacted] វ៉ូន បានធ្វើការឈូសឆាយដីរបស់គាត់ តែការឈូសឆាយនេះបានចូលទៅដីរបស់ឈ្មោះ [redacted] ហៀង ដែលមានទំហំដីទទឹង៤០ម៉ែត្រ បណ្ដោយ១០០ម៉ែត្រ ព្រមទាំងឈូសទំនប់ព្រំដីរាបអស់ពិតមែន ការឈូសឆាយនោះឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន មានត្រាក់ទ័រ០៣គ្រឿង ការឈូសឆាយដីនេះបានធ្វើឱ្យខូចខាតដំណាំឈូក និងទំនប់ព្រំដីរបស់ឈ្មោះ [redacted] ហៀងពិតមែន ។

.សាក្សីឈ្មោះ [redacted] បាន បានឆ្លើយថា កាលដើម ដីនេះស្ថិតនៅថ្លុកជាប់ព្រៃក្រៀង ភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ដីនេះជារបស់ឈ្មោះ [redacted] វុទ្ធី បានលក់ទៅឱ្យឈ្មោះ [redacted] វ៉ូន មានទំហំដី១០០ម៉ែត្រ គុណនឹង ៣៥០ម៉ែត្រ មានព្រំដីជាប់និងឈ្មោះ [redacted] ហៀង នៅ

ខាងកើត ហើយដីរបស់ខ្លួននៅជាប់ដីឈ្មោះ[redacted] វ៉ន នៅខាងត្បូង ដីរបស់ឈ្មោះ[redacted] ហៀង មានទទឹងប្រហែល ១០០ម៉ែត្រ និងបណ្ដោយប្រហែល៥០ម៉ែត្រ គាត់បានដាំឈូសរយៈពេលប្រហែល៥ឆ្នាំទៅ៦ឆ្នាំ ពុំដែលមានអ្នកណាមករករឿងទេ ។

.សាក្សីឈ្មោះ[redacted] ឈុន បានឆ្លើយថា កាលដើមដីនេះរបស់ឈ្មោះ[redacted] វុទ្ធី លក់ទៅឱ្យឈ្មោះ[redacted] វ៉ន ពុំមានទំនាស់គ្នាទេ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩ ឈ្មោះ[redacted] វ៉ន បានធ្វើការឈូសឆាយទៅលើដីដែលគាត់ទិញ និងឈូសចូលទៅដីរបស់ឈ្មោះ[redacted] ហៀង ថែមទៀត បណ្ដាលឱ្យខូចខាតដំណាំឈូករបស់ឈ្មោះ[redacted] ហៀង ពិតមែន ពេលដែលឈ្មោះ អ៊ុត សាវ៉ុន និងឈ្មោះ[redacted] វ៉ន យកត្រាក់ទ័រមកឈូសនេះ ខ្លួនមិនបានដឹងថា ចូលដីរបស់ឈ្មោះ[redacted] ហៀងប៉ុន្មានទេ ។

.សាក្សីឈ្មោះ[redacted] ឈឿន បានឆ្លើយថា រឿងហេតុនេះ ដូចឈ្មោះ[redacted] ឈុន,ឈ្មោះ[redacted] បាន, ឈ្មោះ[redacted] ឌឿន បានឆ្លើយបញ្ជាក់ជូនតុលាការហើយ ខ្លួនក៏ឯកភាពតាមចម្លើយនេះដែរ ខ្លួនមិនចាំថ្ងៃខែទេ ខ្លួនបានឃើញកូនរបស់ឈ្មោះ[redacted] វ៉ន បញ្ជារឱ្យគ្រឿងចក្រចំនួន ០៣គ្រឿង ចូលទៅឈូសឆាយដីរបស់ឈ្មោះ[redacted] ហៀង ពិតមែន ។

.សាក្សីឈ្មោះ[redacted] អាង បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនមិនបានចាំថ្ងៃខែ នោះទេ ក្នុងឆ្នាំ ២០១៨ ឈ្មោះ[redacted] សាវ៉ុន និងឈ្មោះ[redacted] វ៉ន បានបញ្ជារឱ្យគ្រឿងចក្រ ០៣គ្រឿងទៀត មកឈូសឆាយចូលដីរបស់ឈ្មោះ[redacted] ហៀង ពិតមែន ថែមទាំងបានយកថ្នាំបាញ់ស្មៅមកបាញ់លើឈូករបស់របស់ឈ្មោះ[redacted] ហៀង បណ្ដាលឱ្យដំណាំឈូកងាប់អស់ទៀតផង ។

នៅពេលឈ្មោះ[redacted] សាវ៉ុន និងឈ្មោះ[redacted] វ៉ន យកគ្រឿងចក្រចំនួន ០៣គ្រឿង ទៅឈូសឆាយ មានអាជ្ញាធរបានបញ្ជាឱ្យគ្រឿងចក្រទាំងនេះបញ្ឈប់ សកម្មភាពឈូសឆាយដីនេះដែរ ។

.សាក្សីឈ្មោះ[redacted] សុឃី បានឆ្លើយថា កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ ឈ្មោះ[redacted] វ៉ន បានបញ្ជាឱ្យគ្រឿងចក្រចំនួន០៣គ្រឿង បានឈូសឆាយចូលមកដល់ដីរបស់ឪពុកខ្លួន និងបានបំផ្លាញដំណាំឈូក ឪពុកខ្លួន ខ្លួនក៏បានគេប្រាប់អាជ្ញាធរដើម្បីចុះទៅហាមឃាត់ ។

១.អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted] វ៉ន បានឆ្លើយនៅចៅក្រមស៊ើបសួរថា ថ្ងៃពុំចាំក្នុងខែកក្កដា ឆ្នាំ២០១៨ ខ្លួននិងកូនប្រុសឈ្មោះ[redacted] វ៉ន បានទិញដីបឹងឈូក ស្ថិតនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ពីឈ្មោះ[redacted] និងឈ្មោះ ធី (ប្ដីប្រពន្ធ) ដែលមានបណ្ដោយ ៤៥០ម៉ែត្រ និងទទឹង១០០ម៉ែត្រ និង មានព្រំប្រទល់ខាងកើតជាប់នឹងដីរបស់ខ្លួន ខាងត្បូងជាប់នឹងដីឈ្មោះ បាន ខាងលិចជាប់នឹងដី ឈ្មោះ វ៉េត និងឈ្មោះ អ៊ុក (ប្ដីប្រពន្ធ និងដីឈ្មោះ វិត ,ខាងជើងជាប់នឹងដីរបស់ខ្លួន។

ពេលដែលកូនខ្លួនទិញដីនេះវាបានទៅមើលព្រំប្រទល់ជាមួយឈ្មោះ ស៊ីម និងឈ្មោះ ធី ក្នុងការលក់ទិញនេះ កូនខ្លួនធ្វើលិខិត លក់ទិញជាមួយឈ្មោះ ស៊ីម និងឈ្មោះ ធី លោកមេភូមិជាអ្នកធ្វើលិខិតលក់ទិញ ត្រង់លោកមេភូមិចុះ ឬ មិនចុះដល់ដីឈ្មោះ ស៊ីម លក់ឱ្យកូនខ្លួននោះ ខ្លួនពុំបានដឹងទេ ខ្លួនបានប្រគល់លុយឱ្យឈ្មោះ ស៊ីម តែប៉ុណ្ណោះ ។

បច្ចុប្បន្នដីនេះពុំទាន់មានប្លង់ទេ គ្រាន់តែលោកមេភូមិទទួលស្គាល់តែប៉ុណ្ណោះ ក្រោយពេលទិញបានកូនខ្លួនបានដាំឈូកនៅលើដីនោះ ប៉ុន្តែដាំមិនពេញដីទេ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៩ កូនខ្លួនបានជួលត្រាក់ទ័រទៅឈូសកន្ទុយដី និង ទំនប់ក្រោយ ពេលសម្របសម្រួលគ្នានៅអធិការស្រុកជលគីរី ដែលមានប្រវែង១០ម៉ែត្របន្តទៀត ប៉ុន្តែនៅពេលកូនខ្លួនកំពុងឈូសឈ្មោះ អ៊ុង ហៀង និងបក្សពួក ០៧នាក់ បានហាមឃាត់ និងសំឡុតគំរាមគំហែងទៅលើកូនខ្លួនថែមទៀតផង ។



Scanned with CamScanner

២.អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារ៉ុន បានឆ្លើយនៅចៅក្រមស៊ើបសួរថា កាលពីឆ្នាំ២០១៧ ឪពុករបស់ខ្លួនឈ្មោះ [redacted] រ៉ូន បានទិញដីមួយកន្លែងពីឈ្មោះ លោម វុទ្ធី និងឈ្មោះ [redacted] ស៊ីម ទំហំក្បាល១០០ម បណ្តោយ ៤៨០ម ក្នុងតម្លៃ ១៨លាន រៀល ក្រោយមកក្នុងឆ្នាំ២០១៨ ខ្លួនបានទៅធ្វើដីនោះដោយយកត្រាក់ទ័រទៅឈូសឆាយ មានភាគីម្ខាងទៀត មានគ្នាចំនួនប្រហែល ០៧នាក់ ស្គាល់តែឈ្មោះ [redacted] ហៀង ,ឈ្មោះ [redacted] យី និង ហាំ ដោយមានកាំបិតបានប្រមាថ កាប់ចាក់ខ្លួន។

ក្រោយមកខ្លួនក៏បានបញ្ឈប់ការឈូសឆាយ ហើយទៅប្តឹងខាងស្រុកឱ្យជួយដោះស្រាយ ខាងស្រុកបានជួយដោះស្រាយ ពេលនោះខាងស្រុកបានប្រាប់ឱ្យខ្លួនធ្វើតែ ទៅលើដីដែលមានក្បាល ១០០ម និងបណ្តោយ ៤៥០ សិនទៅ ខ្លួនក៏បានយកត្រាក់ទ័រទៅឈូសឆាយម្តងទៀត ហើយខ្លួនក៏បានហៅឈ្មោះ [redacted] ហៀង ឱ្យមើលព្រំ គាត់ថាកុំនិយាយជាមួយអញ ធ្វើតែដីហ្វែងទៅ ពេលនោះខ្លួនក៏បានហៅត្រាក់ទ័រទៅឈូសឆាយលើដីរបស់ខ្លួន ហើយប្រធានសហគមន៍បានតេ សួរមេឃុំ ហើយមេឃុំឱ្យធ្វើត្រឹមតែបណ្តោយ ៤៥០ម សិនទៅ ។

.អំណានចម្លើយសាក្សីឈ្មោះ [redacted] សុយី បានឆ្លើយនៅចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៨ ឈ្មោះ [redacted] រ៉ូន បានបញ្ជាឱ្យគ្រឿងចក្រចំនួន ០៣គ្រឿង មកឈូសឆាយលើដីរបស់គាត់ លុះដល់ម៉ោង១០ គ្រឿងចក្រនោះក៏បានឈូសឆាយចូលមកដល់ដីរបស់ឪពុករបស់ខ្លួន និងបានបំផ្លាញដំណាំឈូក ហើយខ្លួនក៏បានតេប្រាប់ឪពុករបស់ខ្លួន ហើយឪពុករបស់ខ្លួនក៏បានតេប្រាប់អាជ្ញាធរដើម្បីចុះទៅហាមឃាត់ ។

នៅថ្ងៃទី០៣ និងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៩ ឈ្មោះ [redacted] រ៉ូន បានបញ្ជារគ្រឿងចក្រចំនួន ០២គ្រឿងទៀត មកឈូសឆាយដោយបំផ្លាញទំនប់ និងឈូករបស់ខ្លួនប្រហែលជាកន្លះហិចតា ហើយក៏បានធ្វើទំនប់ខិតចូលដីរបស់ខ្លួនដែលមានប្រវែងប្រហែល៤០ម៉ែត្រ ចំពោះការឈូសឆាយខាងលើនេះ អាជ្ញាធរធ្លាប់បានហាមឃាត់រួចហើយ តែឈ្មោះ [redacted] រ៉ូន នៅតែមិនស្តាប់ហើយបន្តធ្វើការឈូសឆាយលើដីរបស់ខ្លួនបន្តទៀត ។

.អំណានចម្លើយសាក្សីឈ្មោះ [redacted] វាសនា បានឆ្លើយនៅនគរបាលយុត្តិថា កាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៧ ឪពុកម្តាយរបស់ខ្លួនបានលក់ដីបឹងឈូកនៅចំនុចជាយត្រែង ឱ្យទៅឈ្មោះ [redacted] រ៉ូន និងឈ្មោះ [redacted] សារ៉ុន ភេទប្រុស រស់នៅភូមិគរជ្រុំ ឃុំកោះថ្កូវ ស្រុកជលគីរី ក្នុងតម្លៃព្រមព្រៀងគ្នា ។ ជាដីបឹងឈូកដែលឪពុកម្តាយលក់នោះមានបណ្តោយប្រវែង ៣៥០ម៉ែត្រ និងមានទទឹងប្រវែង១០០ម៉ែត្រ និងមានព្រំប្រទល់ខាងជើងទល់នឹងដីរបស់ឈ្មោះ [redacted] សុខ ខាងត្បូងទល់នឹងដីឈ្មោះ បាន ទូច ខាងកើតទល់នឹងដីឈ្មោះ [redacted] អាង ,ខាងលិចទល់នឹងឈ្មោះ [redacted] អ៊ុត ។

នៅពេលឪពុកម្តាយខ្លួនគាត់លក់ដីឱ្យឈ្មោះ [redacted] រូន និងឈ្មោះ [redacted] រ៉ុន គាត់អត់បានទៅវាស់ដីនោះទេ ក្នុងពេលដែលខ្លួនវាស់ដីដែលម្តាយឪពុកខ្លួនមានទំនាស់ជាមួយឈ្មោះ [redacted] ហៀង ខ្លួនបានប្រគល់ឱ្យទៅឈ្មោះ [redacted] ហៀង រួចហើយ ដីដែលបញ្ជាក់ឱ្យឪពុកម្តាយខ្លួនលក់ឱ្យឈ្មោះ [redacted] រ៉ូន និងឈ្មោះ [redacted] រ៉ុន គឺមានបណ្តោយប្រវែង៣៥០ម៉ែត្រ និងទទឹងប្រវែង១០០ម៉ែត្រ តែប៉ុណ្ណោះ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបាន សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង និងសាក្សី និង ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រ៉ូន , ឈ្មោះ [redacted] សារ៉ុន នៅពេលសវនាការ ឃើញថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ពិតជាមានអង្គ



Scanned with CamScanner

ហេតុបទល្មើស ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា និង ហិង្សាទៅកាន់កាប់លើអចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ[redacted] វ៉ុន និង ឈ្មោះ[redacted] សាវ៉ុន បានទៅឈូសឆាយដំណាំឈូក និងឈូសទំនប់ព្រំចូលដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង ថែមទៀត មានភស្តុតាងសាក្សី បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនេះជនជាប់ចោទឈ្មោះ [redacted] វ៉ុន និង ឈ្មោះ [redacted] សាវ៉ុន ពិតជាបានយកគ្រឿងចក្រ០៣គ្រឿងទៅឈូសឆាយដីចូលដីរបស់ជនរងគ្រោះពិតមែន ។

តំណាងអយ្យការយល់ឃើញថា ជាប់ចោទឈ្មោះ [redacted] វ៉ុន និងឈ្មោះ[redacted] សាវ៉ុន មានភស្តុតាងគ្រប់គ្រាន់ ក្នុងបទល្មើស ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា និងហិង្សាទៅកាន់កាប់លើអចលនវត្ថុដោយសុចរិត ពិតមែន បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

ដូច្នេះ តំណាងអយ្យការ សូមរក្សាការចោទប្រកាន់ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ: ៤២៥៤/២០ដ.ស.ព ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ និងសុំឱ្យតុលាការសម្រេច ផ្តន្ទាទោសជនជាប់ចោទនេះតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

.លោក អន សម័យ បានសេចក្តីសន្និដ្ឋាន កូនក្តីខ្លួនមានដី ដីដែលមានទីតាំងស្ថិតនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង គឺជាដីកម្មសិទ្ធិរបស់កូនក្តីខ្លួនឈ្មោះ[redacted] ហៀង ដីកូនក្តីខ្លួនមានលិខិតកាន់កាប់តាំងពីឆ្នាំ១៩៩០ មានរដ្ឋអំណាចទទួលស្គាល់ត្រឹមត្រូវ កូនក្តីខ្លួនបានលើកទំនប់ធ្វើជាព្រំ និងដាំឈូករយៈពេល៥ ទៅ៦ឆ្នាំមកហើយ មិនដែលមានជនណាមកតវ៉ាជំទាស់ទេ ដូចសាក្សីបានឆ្លើយបំភ្លឺជូនតុលាការនាពេលសវនាការនេះ តែនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ជនជាប់ចោទឈ្មោះ[redacted] វ៉ុន និងឈ្មោះ[redacted] សាវ៉ុន បានយកគ្រឿងចក្រ០៣គ្រឿងទៅឈូសឆាយដីចូលដីរបស់ជនរងគ្រោះឈ្មោះ[redacted] ហៀង មិនតែប៉ុណ្ណោះ ជនជាប់ចោទឈ្មោះ [redacted] វ៉ុន និងឈ្មោះ[redacted] សាវ៉ុន បានយកថ្នាំបាញ់ស្មៅ ទៅបាញ់សំលាប់ដំណាំឈូករបស់ជនរងគ្រោះចោល ថែមទាំងយកគ្រឿងចាក់ទៅឈូសទំនប់ដែលជាព្រំប្រទល់ចោលចូលមកដីរបស់របស់ជនរងគ្រោះ ។ នៅពេលកើតហេតុ អាជ្ញាធរ សមត្ថកិច្ចបានចុះទៅឃាត់ មិនឱ្យធ្វើសកម្មភាពតទៅទៀត តែជនជាប់ចោទឈ្មោះ [redacted] វ៉ុន និងឈ្មោះ[redacted] សាវ៉ុន មិនព្រមស្តាប់ឡើយ ។

នៅក្នុងរឿងហេតុនេះ កូនក្តីខ្លួនឈ្មោះ [redacted] ហៀង បានខូចខាតដំណាំឈូក និងទំនប់ព្រំប្រទល់ដី ដែលជនជាប់ចោទឈ្មោះ [redacted] វ៉ុន និងឈ្មោះ[redacted] សាវ៉ុន ឈូសបំផ្លាញនេះ ជនរងគ្រោះឈ្មោះ[redacted] ហៀង បានប្តឹងទាមទារសំណងចំនួន៤០(សែសិបលាន)រៀល ខ្លួនជាមេធាវីការពារឱ្យជនរងគ្រោះឈ្មោះ[redacted] ហៀង សុំឱ្យតុលាការផ្តន្ទាទោសទៅលើជនចាប់ចោទនេះតាមច្បាប់ ។

.ក្រោយពីបានស្តាប់ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
.ក្រោយពីបានស្តាប់ ចម្លើយសាក្សី និងអំណានចម្លើយសាក្សី
.ក្រោយពីបានស្តាប់ អំណានចម្លើយជនជាប់ចោទ
.ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
.ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
.ក្រោយពីបានពិនិត្យ លើឯកសារភស្តុតាងនានាក្នុងសំណុំរឿង



Scanned with CamScanner

.ក្រោយពីបានពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ពិតជាមានអង្គហេតុបទល្មើស ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន បានយកគ្រឿងចក្រ០៣គ្រឿងទៅឈូសឆាយដីចូលដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង និងយកថ្នាំបាញ់ស្មៅ ទៅបាញ់សំលាប់ដំណាំឈូករបស់ជនរងគ្រោះនិងឈូសទំនប់ដីព្រំប្រទល់ចោល ចូលមកដីរបស់របស់ជនរងគ្រោះថែមទៀត ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ។

២.អង្គហេតុបទល្មើស ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា ទៅលើជនរងគ្រោះឈ្មោះ [redacted] ហៀង បទល្មើសដែលកើតមានឡើង នៅទីកន្លែងកើតហេតុ និងពេលវេលាដូចខាងលើ ពិតជាបានប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] វ៉ូន និង ឈ្មោះ [redacted] សាវ៉ុន បានយកគ្រឿងចក្រ០៣គ្រឿងទៅឈូសឆាយដីចូលដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង និងយកថ្នាំបាញ់ស្មៅ ទៅបាញ់សំលាប់ដំណាំឈូករបស់ជនរងគ្រោះចោល និងឈូសទំនប់ដីព្រំ ប្រទល់ចោល ចូលមកដីរបស់របស់ជនរងគ្រោះ ពិតប្រាកដមែន តាមការឆ្លើយបំភ្លឺរបស់សាក្សី និងជនរងគ្រោះ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ នៅចំណុចភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ។

៣.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន មានភស្តុតាងសាក្សីឈ្មោះ [redacted] ឌឿន,ឈ្មោះ [redacted] បាន,ឈ្មោះ [redacted] ឈុន,ឈ្មោះ [redacted] ឈឿន,ឈ្មោះ [redacted] អាង និងឈ្មោះ [redacted] សុឃី បានឆ្លើយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន ពិតជាបានយកគ្រឿងចក្រទៅឈូសឆាយដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង ពិតមែន មានភស្តុតាងគ្រប់គ្រាន់ ក្នុងបទល្មើសព្រហ្មទណ្ឌ ដូចដែលដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ពីបទៈពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា តាមដីកាសន្និដ្ឋានស្ថាពរលេខៈ៤២៥៤ ដ.ស.ព ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ឆ្នាំង និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ៤០៦៦/២០ ចុះថ្ងៃទី២៨ ខែធ្នូឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

៤.ជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន បានយកគ្រឿងចក្រ០៣គ្រឿងទៅឈូសឆាយដីព្រំប្រទល់ចោល ចូលដីរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង និង យកថ្នាំបាញ់ស្មៅ ទៅបាញ់សំលាប់ដំណាំឈូករបស់ជនរងគ្រោះចោល ជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន ពិតជាបានប្រព្រឹត្តបទល្មើល ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា ទៅលើទ្រព្យសម្បត្តិរបស់ជនរងគ្រោះឈ្មោះ [redacted] ហៀង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ប្រព្រឹត្តនៅចំណុចភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ពិតប្រាកដមែន ។

៥.តាមអង្គហេតុនៃរឿង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង , លោក [redacted] សម័យ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីឈ្មោះ [redacted] ឌឿន,ឈ្មោះ [redacted] បាន,ឈ្មោះ [redacted] ឈុន,ឈ្មោះ [redacted] ឈឿន,ឈ្មោះ [redacted] អាង និងឈ្មោះ [redacted] សុឃី បានឆ្លើយលើកឡើងនៅពេលសវនាការ មានភាពស៊ីសង្វាក់គ្នា ទៅនឹងភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សាវ៉ុន បានប្រព្រឹត្តបទល្មើស ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនា ទៅលើជនរងគ្រោះឈ្មោះ អ៊ុង ហៀង ប្រព្រឹត្តនៅចំណុចភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ពិតមែន ។



Scanned with CamScanner

៦.សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ សូមរក្សាការចោទប្រកាន់ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ:៩២៥៩/២០ដ.ស.៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ទុកនៅដដែល សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់គប្បីតុលាការពិចារណាតាមច្បាប់ ។

៧.សេចក្តីសន្និដ្ឋានរបស់មេធាវី ការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើង នៅពេលសវនាការនោះ ថា នៅក្នុងអង្គហេតុនេះ ខ្លួនស្នើសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ រីឯសំណងកូនក្តីខ្លួនឈ្មោះ [redacted] ហៀងបានប្តឹងទាមទារសំណងការខូចខាត និងជំងឺចិត្តចំនួន៤០.០០០.០០០.(សែសិបលាន)រៀល គប្បីតុលាការពីចារណាតាមច្បាប់ ។

៨.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង បានប្តឹងទាមទារសំណងជំងឺចិត្ត និងការខូចខាតដំណាំឈូក និងទំនប់ព្រំដី ចំនួន៤០.០០០.០០០.(សែសិបលាន)រៀល និងសុំឱ្យតុលាការផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ គប្បីតុលាការ ពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

៩.មានភស្តុតាងសាក្សីឈ្មោះ [redacted] ឌឿន,ឈ្មោះ [redacted] បាន,ឈ្មោះ [redacted] ឈុន,ឈ្មោះ [redacted] ឈឿន,ឈ្មោះ [redacted] អាង និងឈ្មោះ [redacted] សុឃី បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] វ៉ូន និងឈ្មោះ [redacted] សារ៉ុន បានប្រព្រឹត្តបទល្មើស ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា ទៅលើជនរងគ្រោះឈ្មោះ [redacted] ហៀង ប្រព្រឹត្តនៅចំណុចភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ពិតមែន ។

១០.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ ២៩ឆ្នាំ,ឈ្មោះ [redacted] វ៉ូន ភេទប្រុស អាយុ៦៤ ឆ្នាំ ជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទល្មើស ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

១១.យោងតាមមាត្រា ៤១០ បទធ្វើឱ្យខូចខាតដោយចេតនា៖

.អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀល ទៅ ៤.០០០.០០០(បួនលាន)រៀល លើកលែងតែការខូចខាតមានលក្ខណ:ស្រាល ។

១២.គ្មានអង្គហេតុណាមួយ ដែលអាចបញ្ជាក់ថា ជនជាប់ចោទប្រព្រឹត្ត អំពើហិង្សាទៅលើអ្នកកាន់កាប់លើអចលនវត្ថុដោយសុចរិត តាមមាត្រា២៥៣ នៃច្បាប់ភូមិបាលឡើយ គប្បីតុលាការឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ អំពើហិង្សាទៅលើអ្នកកាន់កាប់លើអចលនវត្ថុដោយសុចរិត តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ។

## ហេតុដូច្នេះសម្រេច

១.ឲ្យរួចខ្លួនពីបទចោទប្រកាន់លើឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ២៩ឆ្នាំ និង ឈ្មោះ [redacted] វ៉ូន ភេទប្រុស អាយុ៦៤ ឆ្នាំ ជាតិខ្មែរ ពីបទហិង្សាទៅលើអ្នកកាន់កាប់លើអចលនវត្ថុដោយសុចរិតតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ។



Scanned with CamScanner

២.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សាវ៉ុន ភេទប្រុស អាយុ២៩ឆ្នាំ និង ឈ្មោះ [redacted] វ៉ុន ភេទប្រុស អាយុ៦៤ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ចំនួន ០១(មួយ)ឆ្នាំ តែទោសនេះព្យួរធម្មតា ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] សាវ៉ុន និង ឈ្មោះ [redacted]វ៉ុន សងសំណងការខូចខាត និងជម្ងឺចិត្ត ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ចំនួន១០.០០០.០០០(ដប់លាន)រៀល ការទាមទារលើសពីនេះបដិសេធចោល ។

.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង និងលោក [redacted] សម័យ ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]សាវ៉ុន និង ឈ្មោះ [redacted]ន និង ប្រកាសសាធារណៈ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ។

.ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កំពង់ឆ្នាំង ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២១
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]